**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងធម្មការនិងសាសនា**
លេខៈ ២២/២៤ ក.ធ.ស សណន

# សេចក្តីណែនាំ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃការប្រឡងជ្រើសរើសសមណសិស្ស សិស្សពុទ្ធិកប្រចាំរាជធានី ខេត្ត និងទូទាំងប្រទេស សម្រាប់ឆ្នាំសិក្សា២០២៤-២០២៥

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា
- បានឃើញប្រកាសលេខ ៦៩/២៤ ក.ធ.ស.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការផ្តល់រង្វាន់ដល់ជ័យលាភីសមណសិស្ស សិស្សពុទ្ធិកផ្នែកភាសាបាលី-សំស្ក្រឹត
- អនុលោមតាមការងារចាំបាច់របស់ក្រសួងធម្មការនិងសាសនា

ដើម្បីពង្រឹងនិងលើកកម្ពស់វិស័យអប់រំផ្នែកពុទ្ធិកសិក្សា ស្របតាមគោលនយោបាយអភិវឌ្ឍមូលធនមនុស្សប្រកបដោយចីរភាព អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនា សូមធ្វើការណែនាំស្តីពីការប្រឡងជ្រើសរើសសមណសិស្ស សិស្សពុទ្ធិកភាសាបាលី-សំស្ក្រឹត ទូទាំងប្រទេស សម្រាប់ពុទ្ធិកមធ្យមសិក្សាទាំងពីរកម្រិត តាមខ្លឹមសារដូចខាងក្រោមៈ

### ១-ការប្រឡងជ្រើសរើសសមណសិស្ស សិស្សពុទ្ធិកប្រចាំរាជធានី ខេត្ត

មន្ទីរធម្មការនិងសាសនា ត្រូវសហការជាមួយសាលាគណរាជធានី ខេត្ត ដើម្បីរៀបចំការប្រឡងជ្រើសរើសសមណសិស្ស សិស្សពុទ្ធិកប្រចាំសាលា លើមុខវិជ្ជាភាសាបាលី-សំស្ក្រឹត សម្រាប់ថ្នាក់ឆ្នាំទី៣ នៃពុទ្ធិកមធ្យមសិក្សាទាំងពីរកម្រិតដែលនឹងប្រព្រឹត្តទៅនៅសប្តាហ៍ទី៤ នៃខែតុលា តាមកម្រិតថ្នាក់និងចំនួនកំណត់ក្នុងតារាងបែងចែកជូនភ្ជាប់មកជាមួយនេះ រួចបញ្ជូនបេក្ខភាពមកចូលរួមប្រឡងជ្រើសរើសសមណសិស្ស សិស្សពុទ្ធិកទូទាំងប្រទេស នៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។



អាសយដ្ឋានៈ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទៈ (៨៥៥-២៣) ៧២២ ៦៩៩
អ៊ីម៉ែលៈ mocargovkh@gmail.com
គេហទំព័រៈ www.mocar.gov.kh

ដោយឡែកពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតត្រូវរៀបចំការប្រឡងជ្រើសរើសសមណសិស្ស សិស្សពូកែ តាមគំនិតច្នៃប្រឌិតផ្ទាល់និងតាមលទ្ធភាពថវិការបស់សាមីសាលា។

គ្រឹះស្ថានពុទ្ធិកមធ្យមសិក្សាត្រូវផ្ញើសំណើប្រធានវិញ្ញាសានិងអត្រាកំណែទៅមន្ទីរធម្មការនិងសាសនា រាជធានី ខេត្ត ដើម្បីធ្វើជាមូលដ្ឋានសម្រាប់រៀបចំប្រធានវិញ្ញាសា មុខវិជ្ជាភាសាបាលី មានរយៈពេល ១២០ នាទី និងភាសាសំស្រ្កឹត មានរយៈពេល ៦០ នាទី។

ប្រធានវិញ្ញាសាប្រឡងជ្រើសរើសសមណសិស្ស សិស្សពូកែប្រចាំរាជធានី ខេត្ត ជាសមត្ថកិច្ចរបស់មន្ទីរធម្មការនិងសាសនារាជធានី ខេត្ត។

សម្រាប់ឆ្នាំសិក្សា២០២៤-២០២៥ មន្ទីរធម្មការនិងសាសនា ត្រូវសហការជាមួយសាលាគណ រាជធានី ខេត្ត ដើម្បីរៀបចំគណៈកម្មការប្រឡងជ្រើសរើសសមណសិស្ស សិស្សពូកែប្រចាំរាជធានី ខេត្ត តាម គំនិតច្នៃប្រឌិតផ្ទាល់និងតាមលទ្ធភាពថវិកា។

## ២-ការប្រឡងជ្រើសរើសសមណសិស្ស សិស្សពូកែទូទាំងប្រទេស

### ២.១-គោលការណ៍រួមនៃការប្រឡង

ក-ការកំណត់កម្រិតថ្នាក់ វិញ្ញាសា និងសម័យប្រឡង

- ការប្រឡងជ្រើសរើសសមណសិស្ស សិស្សពូកែទូទាំងប្រទេសបានកំណត់យកថ្នាក់ឆ្នាំទី៣ នៃពុទ្ធិកមធ្យមសិក្សាទាំងពីរកម្រិត
- វិញ្ញាសាប្រឡងមានភាសាបាលីនិងភាសាសំស្រ្កឹត
- បេក្ខសមណសិស្ស សិស្ស មួយរូបត្រូវប្រឡងពីរវិញ្ញាសា (ភាសាបាលី ឯកទេសទី១ ភាសាសំស្រ្កឹត ឯកទេសទី២)
- កាលបរិច្ឆេទប្រឡង៖ ថ្ងៃចន្ទ-អង្គារ-ពុធ ៣-៤-៥ រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ **ត្រូវនឹងថ្ងៃទី ១៨-១៩-២០ ខែវិច្ឆិកា ឆ្នាំ២០២៤។**
- ប្រធានវិញ្ញាសាប្រឡងជ្រើសរើសសមណសិស្ស សិស្សពូកែទូទាំងប្រទេសរៀបចំដោយអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ដោយគិតតាមកម្មវិធីសិក្សាទាំងពីរភូមិសិក្សា ពីថ្នាក់ឆ្នាំទី១ ដល់ថ្នាក់ឆ្នាំទី៣ សម្រាប់ការប្រឡងសមណសិស្ស សិស្សពូកែទូទាំងប្រទេស។

ខ-ការរៀបចំមណ្ឌលប្រឡង

- មណ្ឌលប្រឡង៖ ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត
- ទីកន្លែងសម្រាប់ប្រារព្ធពិធីបើក ពិធីបិទ ចែកវិញ្ញាបនបត្រនិងរង្វាន់ជ័យលាភីសមណសិស្ស សិស្សពូកែទូទាំងប្រទេស នៅសាលប្រជុំអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ
- យាងព្រះអគ្គាធិការជាព្រះអធិបតីក្នុងពិធីបើកនិងអញ្ជើញរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនាជាអធិបតីក្នុងពិធីបិទ ប្រគេន-ជូនវិញ្ញាបនបត្រនិងរង្វាន់ដល់ជ័យលាភី។

គ-លក្ខខណ្ឌសម្រាប់បេក្ខសមណសិស្ស សិស្សពូកែ

- ត្រូវមានឈ្មោះក្នុងបញ្ជីសមណសិស្ស សិស្សថ្នាក់ឆ្នាំទី៣ ទាំងពីរកម្រិត ក្នុងឆ្នាំសិក្សា២០២៤-២០២៥
- ជាបេក្ខភាព ត្រូវបានជ្រើសរើសនិងបញ្ជូនពីសាមីសាលាដែលទទួលចំណាត់ថ្នាក់ល្អប្រចាំសាលា មុខវិជ្ជាភាសាបាលី-សំស្រ្កឹត
- បេក្ខភាពដែលសាលាបញ្ជូនមកពុំចាំបាច់បែងចែកចំណាត់ថ្នាក់នោះទេ
- ត្រូវចូលរួមជាកំហិតពិធីបើក បិទ ការប្រឡងជ្រើសរើសបេក្ខសមណសិស្ស សិស្សពូកែទូទាំងប្រទេស។

ឃ-ការគ្រប់គ្រងបេក្ខសមណសិស្ស សិស្សពូកែ

ប្រតិភូប្រចាំរាជធានី ខេត្តនីមួយៗ មានភារកិច្ចៈ

- ដឹកនាំគ្រប់គ្រងបេក្ខសមណសិស្ស សិស្សពូកែរបស់ខ្លួន ចាប់តាំងពីពេលចេញដំណើរពីរាជធានី ខេត្តសាមីរហូតដល់ពេលត្រឡប់ទៅវិញ
- រៀបចំការគង់និងស្នាក់នៅរបស់បេក្ខសមណសិស្ស សិស្សពូកែ ឱ្យបានសមស្របតាមគោលការណ៍ចំណាយរបស់សាមីសាលា។

**២.២- ការកំណត់ចំនួនបេក្ខសមណសិស្ស សិស្សពូកែចូលរួមប្រឡងទូទាំងប្រទេស**

| ល.រ | បរិយាយ | ចំនួនសមណសិស្ស សិស្ស | ចំនួនបន្ទប់ | ផ្សេងៗ |
|---|---|---|---|---|
| ១ | ពុទ្ធិកមធ្យមសិក្សាបឋមភូមិ | ១៣២ | ៩ | |
| ២ | ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ | ៥៤ | ៤ | |
| សរុប | | ១៨៦ | ១៣ | |

**សម្គាល់៖** ការកំណត់យកចំនួនបេក្ខភាពដែលជ្រើសរើសចូលរួមប្រឡងសមណសិស្ស សិស្សពូកែទូទាំងប្រទេសទាំងពីរកម្រិតគឺយកចំនួន ៣ រូប ក្នុង ១ ថ្នាក់ ដោយអាស្រ័យទៅលើចំនួនថ្នាក់ជាក់ស្តែងនៅតាមសាលានីមួយៗ។

**២.៣- ការប្រព្រឹត្តទៅនៃដំណើរការប្រឡង**

| កាលបរិច្ឆេទ | សកម្មភាព |
|---|---|
| ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ | ពេលព្រឹក<br>-វេលាម៉ោង ៦:៣០ នាទី ប្រារព្ធពិធីបើកការប្រឡងនៅសាលប្រជុំពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត<br>-វេលាម៉ោង ៧:៣០ នាទី ចាប់ផ្តើមដំណើរការប្រឡងនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត<br>ពេលរសៀល<br>-វេលាម៉ោង ១:០០ នាទី ប្រជុំនិងកែកិច្ចការបេក្ខសមណសិស្ស សិស្ស។ |
| ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤ | ពេលព្រឹក<br>-គណៈកម្មការគ្រប់គ្រងទូទៅប្រជុំសម្រេចលទ្ធផលសម្រាប់ជ័យលាភី<br>-ក្រោយពេលសម្រេចរួច គណៈកម្មការបច្ចេកទេសត្រូវរៀបចំ៖<br>+ បញ្ជីស្ថិតិលទ្ធផលសមណសិស្ស សិស្សពូកែទូទាំងប្រទេស<br>+ ប្រកាសទទួលស្គាល់បេក្ខជនជ័យលាភី ពីលេខ១ ដល់លេខ៣<br>ពេលរសៀល<br>-វេលាម៉ោង ២:៣០ នាទី រៀបចំពិធីបិទការប្រឡង ប្រគេន-ជូនវិញ្ញាបនបត្រនិងរង្វាន់ជ័យលាភីសមណសិស្ស សិស្សពូកែទូទាំងប្រទេស សម្រាប់ឆ្នាំ២០២៤ នៅសាលប្រជុំអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ |

**២.៤- រយៈពេលនិងបេមពិន្ទុនៃវិញ្ញាសាប្រឡង**

- ភាសាបាលី : ១២០ នាទី ១០០ពិន្ទុ
- ភាសាសំស្ក្រឹត : ៦០ នាទី ៥០ពិន្ទុ

### ២.៥- សំណុំលិខិតរបស់បេក្ខសមណសិស្ស សិស្ស

ក្រោយពីសាលាបានប្រឡងជ្រើសរើសនិងប្រកាសលទ្ធផលរួច ត្រូវរៀបចំបំពេញសំណុំលិខិតដាក់ទៅមន្ទីរធម្មការនិងសាសនា រួចមន្ទីរសាមីត្រូវបញ្ជូនសំណុំលិខិតនោះមកអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ដើម្បីចូលរួមប្រឡងជ្រើសរើសសមណសិស្ស សិស្សពូកែទូទាំងប្រទេស មានដូចខាងក្រោម៖

- ពាក្យសុំចុះឈ្មោះប្រឡងសមណសិស្ស សិស្សពូកែទូទាំងប្រទេស ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប ចំនួន ០១ ច្បាប់
- សលាកបត្រឯកត្តជន មានបិទរូបថតទំហំ ៤x៦ ចំនួន ០២ សន្លឹក
- រូបថតថ្មី ៤x៦ (ឃ្លុំចីវរ ឬពាក់អាវស មិនពាក់ក្រវ៉ាត់ក និងមិនពាក់វ៉ែនតា) ចំនួន ០២ សន្លឹក
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត (ថតចម្លង) ចំនួន ០១ ច្បាប់
- វិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា(បាលីរង) សម្រាប់បឋមភូមិ (ថតចម្លង) ចំនួន ០១ ច្បាប់
- សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ(ឌីប្លូម) សម្រាប់ទុតិយភូមិ (ថតចម្លង) ចំនួន ០១ ច្បាប់

➢ **មន្ទីរធម្មការនិងសាសនារាជធានី ខេត្ត ត្រូវផ្ញើមកអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនូវសំណុំឯកសារដូចខាងក្រោម៖**

១-សំណុំលិខិតបេក្ខសមណសិស្ស សិស្សពូកែទូទាំងប្រទេស

២-តារាងបញ្ជីឈ្មោះបេក្ខសមណសិស្ស សិស្សពូកែដែលទទួលស្គាល់ពីសាមីសាលានិងមន្ទីរធម្មការនិងសាសនា (ទាំងSoft ជាWord និងHard) ចំនួន ០១ ច្បាប់

➢ **កាលបរិច្ឆេទផុតកំណត់៖ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ជាកំហិត**

សម្គាល់៖ ចំពោះពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ត្រូវបញ្ជូនសំណុំលិខិតរបស់បេក្ខភាពមកអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

### ២.៦- លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសជ័យលាភីសមណសិស្ស សិស្សពូកែ

- ក្នុងករណីពិន្ទុសរុបមុខវិជ្ជាឯកទេសស្មើគ្នា ត្រូវអញ្ជើញប្រធាន ឬអនុប្រធានកំណែមកកែកិច្ចការនោះសាជាថ្មីឡើងវិញ តាមបែបកំណែសម្ងាត់
- ក្នុងករណីកែឡើងវិញ ពិន្ទុនៅតែស្មើគ្នាទៀត ត្រូវសម្រេចផ្តល់អាទិភាពជូនគណៈមេប្រយោគកំណែជាអ្នកសម្រេច
- គ្រប់សន្លឹកកិច្ចការបេក្ខសមណសិស្ស សិស្សត្រូវកែជារបៀបសម្ងាត់ទាំងអស់ ដោយអ្នកកែពីរនាក់ផ្សេងគ្នា ដាក់ពិន្ទុសម្ងាត់រៀងខ្លួន ហើយពិន្ទុនោះមិនត្រូវសរសេរលើសន្លឹកកិច្ចការរបស់បេក្ខសមណសិស្ស សិស្សឡើយ។ ក្រោយពីកែរួច អ្នកកែត្រូវយករបាយការណ៍ពិន្ទុលម្អិតជាសម្ងាត់នោះមកប្រគល់ជូនប្រធានក្រុមកំណែ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលចុងក្រោយ។

### ២.៧- រង្វាន់ជ័យលាភី

បេក្ខសមណសិស្ស សិស្សគ្រប់រូប ត្រូវទទួលបានវិញ្ញាបនបត្រចូលរួមប្រឡងសិស្សពូកែទូទាំងប្រទេសមួយសន្លឹក។ ចំណែកឯបេក្ខជនជ័យលាភី ត្រូវទទួលរង្វាន់និងការលើកទឹកចិត្តពីរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនានិងព្រះអគ្គាធិការនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ មានដូចខាងក្រោម៖

- ប្រកាសស្តីពីការទទួលស្គាល់សមណសិស្ស សិស្សពូកែ ដោយរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ចំនួន ០១ ច្បាប់
- វិញ្ញាបនបត្របញ្ជាក់បេក្ខសមណសិស្ស សិស្សពូកែទូទាំងប្រទេស ចំនួន ០១ ច្បាប់
- ប្រាក់រង្វាន់លើកទឹកចិត្តតាមចំណាត់ថ្នាក់

**សម្គាល់៖** បេក្ខជនជ័យលាភីអាចមានប្រាក់រង្វាន់ឬសម្ភារៈផ្សេងៗបន្ថែមទៀតពីសប្បុរសជន។

ទទួលបានសេចក្ដីណែនាំនេះ មន្ទីរធម្មការនិងសាសនា សាលាគណ និងគណៈគ្រប់គ្រងសាលាពុទ្ធិកមធ្យមសិក្សាទាំងពីរកម្រិត ត្រូវផ្សព្វផ្សាយដល់សមណសិស្ស សិស្ស ក្នុងរាជធានី ខេត្ត ព្រមទាំងអនុវត្តសេចក្ដីណែនាំនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

ចាយ បូរិន

**កន្លែងទទួល៖**

-សម្ដេចព្រះមហាសង្ឃរាជទាំងពីរគណៈ

-គណៈសង្ឃនាយកទាំងពីរគណៈ

-ក្រសួងធម្មការនិងសាសនា

-មន្ទីរធម្មការនិងសាសនា រាជធានី ខេត្ត

-សាលាគណរាជធានី ខេត្ត

-សាលាអនុគណគ្រប់ ក្រុង ស្រុក ខណ្ឌ

-គ្រប់សាលាពុទ្ធិកមធ្យមសិក្សា

-ឯកសារកាលប្បវត្តិ